# អំណាចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការទាមទារសក្ខីកម្មរបស់សាក្សី

**ដោយ ដេវីដ ឆេហ្ស៊ី និង មៃខល សាលីបា**

*ប្រែសម្រួលដោយ ទេស ម៉ារ៉ែម*

កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញផ្សាយលិខិតជាច្រើនដែលចេញដោយសហចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡេម៉ូន ផ្ញើជូនដល់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ចំនួនប្រាំមួយរូប កោះហៅអ្នកទាំងនេះមកបង្ហាញខ្លួននៅមុខតុលាការដើម្បីផ្តល់សក្ខីកម្ម ក្នុងនាមជាសាក្សីសម្រាប់សំណុំរឿងលេខ០០២ ។ តាមរយៈដំណឹងកាលពីមុនបង្ហាញឲ្យឃើញថា រដ្ឋាភិបាលបានបដិសេធសំណើរពីសហចៅក្រមស៊ើបអង្កេត ។ យោងតាមអ្នកនាំពាក្យរដ្ឋាភិបាល លោក ខៀវ កាញារីទ្ធិ គោលជំហររបស់រដ្ឋាភិបាលគឺថា មានតែមន្ត្រីដែលស្ម័គ្រចិត្តតែប៉ុណ្ណោះដែលតម្រូវឲ្យបង្ហាញខ្លួននៅចំពោះមុខតុលាការ ដោយមិនចាំបាច់គិតថា តើពួកគេត្រូវបានកោះហៅឲ្យធ្វើជាសាក្សីឬក៏អត់នោះទេ ។ លោក ខៀវ កាញារីទ្ធិ បានបន្តទៀតថា មន្ត្រីបរទេសដែលមានវត្តមានចូលរួមក្នុងតុលាការអាច«រៀបចំសម្លៀកបំពាក់ និងវិលត្រឡប់ទៅផ្ទះរបស់គេវិញបាន» ប្រសិនបើមន្ត្រីបរទេសទាំងនេះ មិនពេញចិត្តនឹងសេចក្តីសម្រេចនេះ ។ ថ្មីៗនេះ លោកនាយករដ្ឋមន្ត្រីបានអះអាងថា មន្ត្រីរដ្ឋាភិបាលមិនត្រូវផ្តល់សក្ខីកម្មទេ ពីព្រោះអ្នកទាំងនេះបានចូលរួមក្នុងការបង្កើតតុលាការនេះឡើង ដូច្នេះសក្ខីកម្មរបស់គេក្នុងនាមជា«ដើមចោទ» អាចធ្វើឲ្យតុលាការមានភាពលំអៀង ។

នៅក្នុងដំណាក់កាលនេះ វាពិតជាមានសារសំខាន់ដែលថា គួរតែមានការស្វែងយល់ឲ្យច្បាស់លាស់មួយដោយអ្នកចូលរួមពាក់ព័ន្ធទាំងអស់ក្នុងនីតិវិធីដែលកំពុងតែអនុវត្តដោយ អ.វ.ត.ក និងការស្វែងយល់ពីមូលហេតុដែលសាក្សីរបស់រដ្ឋាភិបាល អាចនឹងក្លាយជាប្រយោជន៍ដល់សហចៅក្រមស៊ើបអង្កេតដោយមិនមែនក្នុងនាមជាដើមចោទ និងចុងចោទទេ ប៉ុន្តែក្នុងនាមជាសាក្សី ដែលអាចជួយក្នុងការបញ្ជាក់ពីការពិត ស្របពេលដែលភស្តុតាងកំពុងតែត្រូវបានប្រមូល ដើម្បីធ្វើការចោទប្រកាន់លើជនសង្ស័យទាំងបួនរូប ដែលកំពុងត្រូវបានស៊ើបអង្កេតនៅក្នុងសំណុំរឿងលេខ ០០២ ។

## អំណាចតាមផ្លូវច្បាប់របស់ អ.វ.ត.ក ក្នុងការទទួលបានសក្ខីកម្មរបស់សាក្សី

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាលើការស្ថាបនាអង្គជំនុំជម្រះនេះឡើង បានកំណត់យ៉ាងដាក់លាក់ថា នីតិវិធីត្រូវតែស្របទៅតាមច្បាប់កម្ពុជា ។ សេចក្តីណែនាំចេញពីច្បាប់នីតិវិធីអន្តរជាតិអាចនឹងតម្រូវឲ្យមានខណៈពេលដែលច្បាប់កម្ពុជាមិនមានភាពស៊ីចង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ ឬខណៈពេលដែលមិនមានភាពច្បាស់លាស់ទាក់ទិននឹងការបកប្រែនៃបទដ្ឋាននីតិវិធីដែលជាប់ពាក់ព័ន្ធតាមច្បាប់កម្ពុជា ។ ច្បាប់ឆ្នាំ២០០៤ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានផ្តល់សិទ្ធិអំណាចដល់សហចៅក្រមស៊ើបអង្កេតដើម្បីស្តាប់សាក្សី ស្របទៅតាមនីតិវិធីជាធរមានដែលមាន ។ លើសពីនេះ ឯកសារត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញរបស់ អ.វ.ត.ក ចែងថា សហចៅក្រមស៊ើបអង្កេតដោយគ្មានជាប់ពាក់ព័ន្ធនឹងការទទួលបន្ទុកក្នុងការបំពេញការងាររបស់គេ (ដូចជា ការស្តាប់សក្ខីកម្មរបស់សាក្សី) អាចនឹងស្នើសុំកិច្ចសហការពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងករណីដែលកិច្ចសហការបែបនេះត្រូវតែផ្តល់ឲ្យជាដាច់ខាត ។

អង្គបុរេជំនុំជម្រះ បានកំណត់ថា មានតែវិធានផ្ទៃក្នុងទេដែលអាចបង្កើតជាប្រភពដែនអាជ្ញាធររបស់ច្បាប់នីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាន មិនមែនក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាទេ ។ អង្គបុរេជំនុំជម្រះ បានប្រកាន់គោលជំហរថា វិធានផ្ទៃក្នុងអាចបង្កើតរបបនៃក្រមនីតិវីធីចំណុះផ្ទាល់ខ្លួនដែលតម្រូវឲ្យមានក្នុងករណីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីព្រោះថា ការសង្កត់ធ្ងន់របស់តុលាការ មានភាពខុសគ្នាពីប្រតិបត្តិការជាទូទៅរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ។ យ៉ាងណាមិញ វាក៏គួរឲ្យកត់សម្គាល់យ៉ាងសំខាន់ផងដែរថា ទាំងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពិតជាមានភាពស៊ីចង្វាក់គ្នាច្រើនលើច្បាប់នេះ ។ ជាមួយគ្នានេះដែរវិធានទាំងពីរនេះបានផ្តល់សិទ្ធិអំណាចដ៏ធំធេងដល់សហចៅក្រមស៊ើបអង្កេត ដើម្បីកោះហៅសាក្សីមកផ្តល់សក្ខីកម្មនៅចំពោះមុខក្នុងកិច្ចការស៊ើបអង្កេតរបស់គេ ។

វិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេត អាចដកស្រង់យកសេចក្តីរាយការណ៍ពីជនទាំងឡាយណាដែលសក្ខីកម្មរបស់គេត្រូវបានចាត់ទុកថា «នាំមកនូវលទ្ធផលល្អក្នុងការបញ្ជាក់ពីការពិត» ។ ជនទាំងឡាយណាដែលត្រូវបានកោះហៅមកធ្វើជាសាក្សី ត្រូវតែមកបង្ហាញខ្លួននៅចំពោះសហចៅក្រមស៊ើបអង្កេត ។ ក្នុងករណីបដិសេធមិនមកបង្ហាញខ្លួន សហចៅក្រមស៊ើបអង្កេតអាចចេញបទបញ្ជាមួយស្នើសុំឲ្យមន្ត្រីនគរបាលយុត្តិធម៌បង្ខំសាក្សីឲ្យមកបង្ហាញខ្លួនបាន ។ បន្ថែមលើនេះ ដោយគ្មានករណីលើកលែងការបដិសេធមិនធ្វើសក្ខីកម្ម អាចចាត់ទុកថាជាការអន្តរាគមន៍មួយលើការគ្រប់គ្រងវិស័យយុត្តិធម៌ ។

ក្នុងករណីទាំងនេះ សហចៅក្រមស៊ើបអង្កេតអាចរៀបចំការស៊ើបអង្កេតបន្តទៀតដើម្បីបញ្ជាក់ថា មានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ដំណើរការស៊ើបអង្កេត ឬក៏សហចៅក្រមស៊ើបអង្កេត អាចនឹងបញ្ជូនបញ្ហានេះទៅកាន់អាជ្ញាធររបស់ព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិបាន។ ទណ្ឌកម្មដែលត្រូវបានដាក់លើសាក្សីសម្រាប់ការអន្តរាគមន៍លើការគ្រប់គ្រងវិស័យយុត្តិធម៌ នឹងត្រូវកំណត់ដោយច្បាប់កម្ពុជា ។

បើទោះបីជាវិធានផ្ទៃក្នុងមានអភិបាលកិច្ចគ្រប់គ្រងលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏ដោយ ក៏វានៅតែមានសារសំខាន់ក្នុងការកត់សម្គាល់ថា វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពិតជា មានភាពស៊ីចង្វាក់គ្នាច្រើនលើច្បាប់នេះ ។ ជាក់ស្តែង ចៅក្រមស៊ើបអង្កេតអាចចោទសួរជនទាំងឡាយណាដែលការឆ្លើយតបរបស់គេមានប្រយោជន៍ក្នុងការលាតត្រដាងពីការពិត ។ ជនទាំងឡាយណាដែលត្រូវបានកោះហៅមកធ្វើជាសាក្សី ត្រូវតែមកបង្ហាញខ្លួននៅចំពោះចៅក្រមស៊ើបអង្កេត ។ ប្រសិនបើជននោះបដិសេធមិនមកបង្ហាញខ្លួននោះ ចៅក្រមស៊ើបអង្កេតអាចស្នើសុំឲ្យកម្លាំងសមត្ថកិច្ចសាធារណៈបង្ខំសាក្សីនោះមកបង្ហាញខ្លួន ។ ចំណែកកម្លាំងសមត្ថកិច្ចសាធារណៈវិញ ត្រូវតែធ្វើសកម្មភាពឲ្យស្របទៅតាមការបង្គាប់បញ្ជារបស់ចៅក្រមស៊ើបអង្កេត ។ ការអាក់ខានមិនបានមកបង្ហាញខ្លួននៅក្នុងតុលាការ ឬផ្តល់ព័ត៌មានក្នុងនាមជាសាក្សី អាចនឹងត្រូវដាក់ទណ្ឌកម្មយោងទៅតាមច្បាប់ ។ ទណ្ឌកម្មសម្រាប់ការបដិសេធមិនធ្វើសក្ខីកម្ម ទំនងជាត្រូវបានដាក់ជាបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌកម្ពុជាថ្មី ដែលមាត្រាព្រាងរបស់ក្រមព្រហ្មទណ្ឌទាំងនេះ ត្រូវបានទទួលស្គាល់ដោយរដ្ឋសភាជាតិកាលពីថ្ងៃទី១២ ខែតុលា ។ ក្រមព្រហ្មទណ្ឌដែលត្រូវបានអនុម័តកាលពីឆ្នាំ១៩៩២ ដោយអាជ្ញាធរអន្តរកាលរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជានេះ បានដាក់ពិន័យជនទាំងឡាយណា ដែលអាក់ខានមិនមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ។

## បទដ្ឋានរបស់អ.វ.ត.ក ក្នុងការស្តាប់សក្ខីកម្មរបស់សាក្សី

វិធានផ្ទៃក្នុង ផ្តល់សិទ្ធិអំណាចដល់សហចៅក្រមស៊ើបអង្កេតតាមខបញ្ញត្តិក្នុងការទទួលបានសក្ខីកម្មពីសាក្សីទៅតាមបទដ្ឋានដ៏ធំធេងមួយពី “អត្ថប្រយោជន៍ក្នុងការបញ្ជាក់ពីការពិត” ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀត បានប្រកាន់គោលជំហរថា បើទោះបីជាសាក្សីម្នាក់អាចនឹងផ្តល់ភស្តុតាងដែលអាចទទួលយកបាន និងដែលមានជាប់ពាក់ព័ន្ធក៏ដោយ ក៏ដីកាកោះហៅសាក្សី ត្រូវតែផ្ញើជូន

ខណៈពេលដែលវាទំនងជាអាចទទួលបានព័ត៌មានទាក់ទិននឹងភស្តុតាងលើអង្គហេតុមួយ ក្នុងករណីដែលភស្តុតាងនោះមិនអាចទទួលយកបានដោយគ្មានការអន្តរាគមន៍ពីតុលាការ ឬតាមរយៈមធ្យោបាយផ្សេងៗទៀត ។ យ៉ាងណាមិញ ដោយមានភាពជាក់លាក់ខ្ពស់បំផុត លក្ខន្តិកៈ និងបទដ្ឋានសម្រាប់ការកំណត់សម្គាល់ដែល«ពឹងផ្អែកចុងក្រោយបង្អស់» នេះគឺថា មាតិកានៃសក្ខីកម្មរបស់សាក្សី គឺត្រូវបានបង្កើតចេញពីវិធាននីតិវិធី និងភស្តុតាងពីតុលាការអន្តរជាតិដែលមានភាពខុសគ្នាគួរឲ្យកត់សម្គាល់ពីវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដោយមានការគោរពលើការបង្ខំយកសក្ខីកម្មរបស់សាក្សី ។

វិធាននីតិវិធី និងភស្តុតាងសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និង រ៉្វាន់ដា និងតុលាការពិសេសសម្រាប់ សេរ៉ាឡេអូន ចែងក្នុងផ្នែកដែលជាប់ពាក់ព័ន្ធថា ចៅក្រម ឬអង្គជំនុំជម្រះសាលាដំបូង អាចចេញបទបញ្ជា ការកោះហៅ ដីការកោះហៅសាក្សី ដីការអនុញ្ញាតធ្វើការឆែកឆេរ និងអាចបញ្ជូនបទបញ្ជាទាំងនេះបាន ពីព្រោះការធ្វើបែបនេះអាចនឹងមានអត្ថប្រយោជន៍ដល់គោលដៅស៊ើបអង្កេត ឬដល់ការរៀបចំ ឬប្រតិបត្តិការរបស់តុលាការបាន ។ លក្ខន្តិកៈដែល “ពឹងផ្អែកចុងក្រោយគេ” ឬលក្ខន្តិកៈព័ត៌មានដែលព្យាយាមស្វែងរកមិនអាចទាញយកបានតាមមធ្យោបាយផ្សេងៗនោះ ត្រូវបានបញ្ចូលទៅក្នុងយុត្តាធិការអន្តរជាតិដោយសារតែលក្ខន្តិកៈបញ្ញត្តិដែលធ្វើឲ្យការកោះហៅមានសារប្រយោជន៍ដល់គោលដៅស៊ើបអង្កេត ឬការរៀបចំ ឬប្រតិបត្តិរបស់តុលាការ ។ បញ្ញត្តិរបស់ អ.វ.ត.ក គឺមានភាពសេរីនិយមច្រើន និងផ្តល់អំណាចដល់សហចៅក្រមស៊ើបអង្កេតដើម្បីស្តាប់សក្ខីកម្មរបស់សាក្សី ខណៈពេលដែលសក្ខីកម្មនេះអាចនាំមកនូវលទ្ធផលល្អជាងប្រយោជន៍ក្នុងការបញ្ជាក់ពីការពិត ។ បន្ថែមលើនេះ បញ្ញត្តិរបស់ អ.វ.ត.ក ផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេតនូវភាពរវាសរវៃក្នុងការបង្ខំយកសក្ខីកម្មរបស់សាក្សី បើទោះបីជានៅពេលដែលព័ត៌មានដែលបានព្យាយាមស្វែងរកនោះមិនទាន់បានផ្សារភ្ជាប់ដោយច្បាស់លាស់ជាមួយនឹងអង្គហេតុដែលបានកំណត់យ៉ាងច្បាស់ក្នុងដំណើរការស៊ើបអង្កេត ឬដំណើរការរបស់តុលាការនាពេលខាងមុខក៏ដោយ ។

លើសពីនេះ ក្នុងដំណាក់កាលស៊ើបសួរ បើពិចារណាឃើញថា វាមានភាពឆាប់រហ័សពេកនៅក្នុងដំណើរការប្រតិបត្តិ នោះវាក៏នៅតែមានសារសំខាន់បំផុតក្នុងការផ្តល់សេរីភាពដល់សហចៅក្រមស៊ើបអង្កេតក្នុងការប្រមូលភស្តុតាងដែលអាចបំភ្លឺការពិតជុំវិញដំណើរការស៊ើបអង្កេតរបស់គេ ។ អំណាចក្នុងការស្វែងរកព័ត៌មានដ៏ធំធេងមួយរបស់សហចៅក្រមស៊ើបអង្កេតដើម្បីស្តាប់សក្ខីកម្មរបស់

សាក្សី អាចនឹងមានភាពស៊ីចង្វាក់គ្នាជាមួយនឹងសមាជប្រជុំអន្តរជាតិ ស្តីពីសិទ្ធិក្នុងផ្នែកនយោបាយ និងសិទ្ធិជាពលរដ្ឋដែលត្រូវបានដកលទៅក្នុងឯកសាររដ្ឋធម្មនុញ្ញរបស់ អ.វ.ត.ក និងក្នុងប្រទេសដែលក្នុងផ្នែកនោះជនជាប់ចោទមានសិទ្ធិមួយក្នុងការទទួលយកវត្តមាន និងការត្រួតពិនិត្យរបស់សាក្សីដែលចោទប្រកាន់លើជនជាប់ចោទជំនួសឲ្យជនជាប់ចោទខ្លួនឯងផ្ទាល់ក្រោមលក្ខខណ្ឌដូចគ្នា ។

## ការអនុញ្ញាតមិនធ្វើសក្ខីកម្ម

តុលាការ គួរតែចេញដីការកោះហៅសាក្សីក្នុងករណីដែលសក្ខីកម្មរបស់សាក្សីអាចនាំមកនូវលទ្ធផលល្អសម្រាប់ការបញ្ជាក់ពីការពិត ។ សក្ខីកម្មដែលព្យាយាមស្វែងរកសម្រាប់ហេតុផលផ្សេងៗ ដូចជា សម្រាប់គោលបំណងផ្នែកនយោបាយដើម្បីធ្វើឲ្យមន្ត្រីសាធារណៈមានភាពអាម៉ាស់ អាចនឹងចាត់ទុកថាជាការរំលោភបំពានដល់ដំណើរការ ហើយអាចនឹងក្លាយជាការអនុវត្តអំណាចកោះហៅសាក្សីដែលមិនមានភាពសមរម្យមួយ ។ យ៉ាងណាមិញ ខណៈណាដែលសាក្សីត្រូវបានកោះហៅមកបង្ហាញខ្លួនដោយសមរម្យហើយ សាក្សីនោះត្រូវតែធ្វើសក្ខីកម្ម ប្រសិនបើសាក្សីមិនមាន “ករណីលើកលែងប្រកបដោយយុត្តិធម៌” ។ បន្ថែមលើនេះ កាតព្វកិច្ចក្នុងការមកបង្ហាញខ្លួនជាសាក្សីនៅពេលដែលត្រូវបានកោះហៅនោះ នឹងលាត សន្ធឹងលើក្រុមមន្ត្រីរដ្ឋាភិបាល ។

មានតែករណីលើកលែងដែលត្រូវបានចែងដោយផ្ទាល់នៅក្នុងវិធានផ្ទៃក្នុងទេ គឺត្រូវបានទទួលស្គាល់ជាទូទៅពីសិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯង ។ ជាក់ស្តែង គ្មានសាក្សីណាម្នាក់ អាចនឹងត្រូវបានបង្ខំឲ្យធ្វើសេចក្តីរាយការណ៍ដែលអាចដាក់ពិរុទ្ធភាពលើខ្លួនគេឡើយ ។ ដើម្បីបញ្ជាក់ឲ្យប្រាកដ មន្ត្រីរដ្ឋាភិបាលទាំងប្រាំមួយរូប អាចនឹងមានកាតព្វកិច្ចធ្វើសក្ខីកម្មក្នុងនាមជាសាក្សី និងមិនមែនជាជនសង្ស័យទេ ។ ជាមួយគ្នានេះ អ្នកទាំងអស់នេះ អាចបដិសេធមិនឆ្លើយនឹងសំណួរណាដែលអាចដាក់ពិរុទ្ធភាពលើខ្លួនគេបាន ។ ក្រៅពីសិទ្ធិនេះ យុត្តាធិការអន្តរជាតិ ទទួលស្គាល់ “មូលហេតុប្រកបដោយយុត្តិធម៌” ដទៃផ្សេងៗទៀតដែល អ.វ.ត.ក អាចនឹងបញ្ចូលទៅក្នុងការកំណត់របស់ខ្លួនថា សាក្សីដែលត្រូវបានកោះហៅបង្ហាញខ្លួន អាចនៅតែត្រូវបានអនុញ្ញាតមិនធ្វើសក្ខីកម្ម ។

ជាឧទាហរណ៍ សេចក្តីសម្រេចជាច្រើនចេញពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានទទួលស្គាល់ថា សាក្សីដែលត្រូវបានកោះហៅមកបង្ហាញខ្លួន អាចអនុញ្ញាតមិនធ្វើសក្ខីកម្ម ក្នុងករណីដែលសក្ខីកម្មរបស់

គេអាចមានផលប៉ះពាល់ធ្ងន់ធ្ងរលើសុខភាពសតិអារម្មណ៍ ឬសុខភាពផ្លូវកាយរបស់គេ ។ យោងតាមសេចក្ដីសម្រេចទាំងនេះ ផលប៉ះពាល់ដ៏មានគ្រោះថ្នាក់លើសុខភាពរបស់សាក្សី គឺជាការព្រួយ បារម្ភខ្លាំងបំផុតមួយដែលរារាំងដល់តុលាកាក្នុងការចេញដីការកោះហៅសាក្សី ។

បន្ថែមលើនេះ សាក្សីជាច្រើននៅឯតុលាការខុក្រិដ្ឋកម្មអន្តរជាតិដទៃទៀត បានបដិសេធមិនធ្វើសក្ខីកម្ម ពីព្រោះអ្នកទាំងនេះភ័យខ្លាចចំពោះសុវត្ថិភាពរបស់គេ និងអំពើអហឹង្សាសងសឹងមកលើគ្រួសាររបស់គេ ។ យ៉ាងណាមិញ ការព្រួយបារម្ភសម្រាប់សុវត្ថិភាពរបស់គេ និងសាច់ញាតិគេមិនបានផ្លាស់ប្ដូរតួនាទីមកធ្វើសក្ខីកម្មរបស់គេដោយស្វ័យប្រវត្តិបានឡើយ ។ ក្នុងករណីទាំងនេះ តុលាការ ត្រូវតែដោះស្រាយបញ្ហាព្រួយបារម្ភពីសុវត្ថិភាពរបស់សាក្សី និងអនុវត្តវិធានការការពារក្នុងចំណោមវិធានការផ្សេងៗទៀតដូចជា ការផ្ដល់ជាដំណើរការនីតិវិធីដោយសម្ងាត់ ឬការធ្វើសក្ខីកម្មដោយការថតជាខ្សែវីឌីអូ ។ ក្នុងចំណុចនេះ មិនមានព័ត៌មានសាធារណណាមួយដែលស្នើសុំថាសក្ខីកម្មរបស់មន្ត្រីរដ្ឋាភិបាលទាំងប្រាំមួយរូបក្នុងករណីនេះ អាចនឹងធ្វើឲ្យអ្នកទាំងនេះ និងសមាជិកគ្រួសាររបស់គេស្ថិតក្នុងភាពគ្រោះថ្នាក់ឡើយ ។

ក្នុងកាលៈទេសៈដែលមានព្រំដែន តុលាការខុក្រិដ្ឋកម្មអន្តរជាតិ បានយល់ឃើញថា ការព្រួយបារម្ភលើគោលនយោបាយសាធារណៈមួយចំនួន អាចក្លាយជាកត្តាដ៏មានសារសំខាន់ប្រឆាំងលើការបង្ខំយកសក្ខីកម្មរបស់សាក្សី ។ ជាឧទាហរណ៍ អ្នកស៊ើបការណ៍ពីសង្គ្រាម រីករាយជាមួយនឹងកម្រិតថ្នាក់ដ៏ខ្ពស់នៃការការពារខ្លួនរបស់គេពីការមិនធ្វើសក្ខីកម្ម ពីព្រោះថា ការបង្ខំឲ្យធ្វើសក្ខីកម្មត្រឡប់មកវិញ អាចនឹងប៉ះពាល់ដល់សមត្ថភាពរបស់គេ ក្នុងការបំពេញការងារដែលត្រូវបានចាត់ទុកជាអត្ថប្រយោជន៍ជាសាធារណៈដ៏សំខាន់មួយ ។ ផ្ទុយពីការព្រួយបារម្ភពីគោលនយោបាយសាធារណៈជាក់លាក់ណាមួយដែលមិនទាក់ទងនឹងករណីនេះ អ.វ.ត.ក មានអំណាចក្នុងការប៉ាន់ប្រមាណមើលលើការព្រួយបារម្ភពីគោលនយោបាយសាធារណៈរបស់ខ្លួន ។ យ៉ាងណាមិញ ការព្រួយបារម្ភពីគោលនយោបាយសាធារណៈត្រូវតែមានភាពប្រាកដប្រជា ហើយវាគឺជាគោលនយោបាយសម្រាប់តុលាការ មិនមែនសម្រាប់សាក្សីទេ ក្នុងការសម្រេចថាតើ ការព្រួយបារម្ភពីគោលនយោបាយសាធារណ អាចក្លាយជាការអនុញ្ញាតឲ្យសាក្សីមិនធ្វើសក្ខីកម្មឬយ៉ាងណា ។

**សេចក្ដីសន្និដ្ឋាន**

ទោះបីជាមានការបដិសេធដែលបានលើកឡើងដោយមន្ត្រីរដ្ឋាភិបាលចម្បងៗក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចនឹងអនុវត្តអំណាចរបស់ខ្លួនដោយសមហេតុផលក្នុងការកោះហៅសាក្សីមកបង្ហាញខ្លួនឲ្យតែសក្ខីកម្មដែលព្យាយាមស្វែងរក គឺចាត់ទុកថាអាចនាំមកនូវលទ្ធផលល្អក្នុងការបញ្ជាក់ពីការពិត ។ ខណៈពេលដែលត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួនរៀបរយហើយ សាក្សី រួមទាំងមន្ត្រីរដ្ឋាភិបាល មានកាតព្វកិច្ចមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ប្រសិនបើអ្នកទាំងនេះមិនអាចបង្ហាញមូលហេតុត្រឹមត្រូវ ។ មន្ត្រីរដ្ឋាភិបាលទាំងប្រាំមួយរូប មិនទាន់បានបញ្ជាក់ឲ្យច្បាស់ថាតើពួកគេនឹងគោរពតាមលិខិតរបស់សហចៅក្រមស៊ើបអង្កេត ឬថាតើពួកគេគួរតែសម្រេចមិនគោរពតាមលិខិតនេះដោយផ្អែកលើមូលដ្ឋានសម្រេចចិត្តរបស់គេដែរឬក៏អត់នោះទេ ។ ដូច្នេះ រហូតទាល់តែដល់ពេលដែលពួកគេអាចបញ្ជាក់ និងបង្ហាញពីមូលហេតុត្រឹមត្រូវ នោះ មន្ត្រីទាំងប្រាំមួយរូបនេះមានកាតព្វកិច្ចមកបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដើម្បីផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី ។ បន្ថែមលើនេះ ប្រសិនបើពួកគេអាក់ខានមិនបានមកបង្ហាញខ្លួនដោយមូលហេតុត្រឹមត្រូវ នោះនឹងមានលទ្ធភាពដែលថា ពួកគេអាចនឹងដាក់ឲ្យទទួលរងទណ្ឌកម្មតាមច្បាប់កម្ពុជា ។ វានៅតែមានភាពបន្ទាប់បញ្ជារដែលថា តុលាការឧក្រិដ្ឋកម្មអន្តរជាតិក្រៅពីប្រទេសកម្ពុជា បានធ្វើការកាត់ទោសចំពោះសាក្សីជាច្រើនដែលមានបំណងបដិសេធមិនផ្តល់សក្ខីកម្ម និងបានចេញដីកាឃុំខ្លួនរួមទាំងរយៈពេលឃុំឃាំងក្នុងពន្ធនាគារផងដែរ ។